ទីស្តីការក្រសួងយុត្តិធម៌

លេខ ១១២៣ រវ៣.៦យ-២០០២

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

# <u>សេចក្តីណែនាំ</u>

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## <u>ផ្ញើជូនចំពោះ</u>

**លោកប្រធានតុលាការ ខេត្ត-ក្រុង**

**លោកព្រះរាជអាជ្ញាអមតុលាការ ខេត្ត-ក្រុង**

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ:</u>** អំពីការចេញសាលក្រមប្រកាសបណ្តឹងសម្រេចកែប្រែ ឬ ផ្លាស់ប្តូរឈ្មោះ ឬកែប្រែអាយុ ។

**<u>យោង:</u>** សម្រង់សាលក្រមប្រកាសបណ្តឹងលេខ១៥ ច ចុះថ្ងៃទី២៨-០១-២០០២ របស់តុលាការក្រុងភ្នំពេញ ។

-លិខិតលេខ១៧២ សជណ ចុះថ្ងៃទី១៣-០៩-២០០២ របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

-អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩-១២-២០០០ ស្តីពីអត្រានុកូលដ្ឋាន ។

-អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២៤-០៦-២០០២ ស្តីពីការកែសម្រួលមាត្រា ៨ និងមាត្រា៥៩ នៃ អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩-១២-២០០០ ។

-លិខិតលេខ ១០២៨ រវណ.កយ ចុះថ្ងៃទី១៨-១០-២០០២ របស់ក្រសួងយុត្តិធម៌ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាគ្រប់ខេត្ត-ក្រុង ជ្រាបថា បច្ចុប្បន្ននេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចេញអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩-១២-២០០០ និងអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤-០៦-២០០២ ស្តីពីអត្រានុកូលដ្ឋាន ដែលកំណត់អោយប្រជាពលរដ្ឋរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បំពេញកាតព្វកិច្ចជូនរដ្ឋក្នុងការចុះបញ្ជីជាតិកំណើត ចុះបញ្ជីអាពាហ៍ពិពាហ៍ និងចុះបញ្ជីមរណភាព ។

មាត្រា ១៧ និង មាត្រា ២៥ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩-១២-២០០០ បានកំណត់ឲ្យប្រជាពលរដ្ឋកម្ពុជា ដែលមានទារកទើបនឹងកើត មានកាតព្វកិច្ចទៅប្តឹងចុះបញ្ជីជាតិកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានមិនអោយហួសរយៈពេល៣០ថ្ងៃ។ក្នុងករណីទុកអោយហួសរយៈពេល៣០ថ្ងៃ មន្ត្រីអត្រានុកូលដ្ឋានអាចចុះបញ្ជីកំណើតអោយទារកនោះបានលុះត្រាណាតែមានសាលក្រមពីតុលាការខេត្ត-ក្រុង សាមី ។

មានត្រា ៥៩ ថ្មី នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២៤-០៦-២០០២ បានកំណត់ថា ការសុំបញ្ជាក់អត្រានុកូលដ្ឋាន ត្រូវបានអនុវត្តន៍ចំពោះតែពលរដ្ឋខ្មែរហើយអនុវត្តន៍តែក្នុងរយៈពេល៣ឆ្នាំ គិតចាប់ពីថ្ងៃទី០១-០៨-២០០២ ដល់ថ្ងៃទី៣១-០៨-២០០៥ ។ ផុតរយៈពេលនេះប្រជាពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានត្រូវទៅសុំសាលក្រមពីតុលាការខេត្ត-ក្រុង សាមី ។

ផ្អែកតាមមាត្រាទាំង ៣ នៃអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ដូចបានជម្រាបជូនខាងលើដែលកំពុងនៅជាធរមាន នេះក្រសួងយុត្តិធម៌បានពិនិត្យឃើញថា អនុក្រឹត្យនេះមានចែងសម្រាប់តែប្រជាពលរដ្ឋកម្ពុជា ដែលមានទារកទើបនឹងកើត ឬ ទើបរៀបអាពាហ៍ពិពាហ៍ ឬ ទើបទទួលមរណភាព រួមជាមួយប្រជាពលរដ្ឋ ដែលបានចុះបញ្ជីអត្រានុកូលដ្ឋានរួចហើយ ប៉ុន្តែត្រូវបាត់បង់នៅក្នុងរបបប៉ុលពត ឬ ពុំទាន់បានចុះបញ្ជីអត្រានុកូលដ្ឋាន ចាប់ពីថ្ងៃទី១៧-០៤-១៩៧៥

រហូតដល់អនុក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិតែប៉ុណ្ណោះ ដោយពុំមានមាត្រាណាមួយចែងអោយប្រជាពលរដ្ឋកម្ពុជាប្តឹងសុំអោយតុលាការសម្រេចកែប្រែ ឬ ផ្លាស់ប្តូរឈ្មោះ ឬ កែប្រែអាយុខុសពីប្រវត្តិជាតិកំណើតរបស់ខ្លួនឡើយ ។

កន្លងមកក្រសួងយុត្តិធម៌ តែងបានពិនិត្យឃើញតុលាការខេត្ត-ក្រុង មួយចំនួនចេញសាលក្រមប្រកាសបណ្តឹងដោយសម្រេចសេចក្តីអោយប្រជាពលរដ្ឋ ឬ មន្ត្រីរាជការកែប្រែ ឬ ផ្លាស់ប្តូរឈ្មោះ ឬ កែប្រែអាយុខុសពីប្រវត្តិជាតិកំណើតរបស់ខ្លួនតាមពាក្យប្តឹងសុំរបស់ម្ចាស់បណ្តឹង ដោយពុំមានមូលដ្ឋានច្បាប់ជាបង្អែកឡើយ ដែលជាហេតុធ្វើឱ្យសាលក្រមរបស់តុលាការនោះមានផលប៉ះពាល់ដល់គោលនយោបាយកំណែទម្រង់រដ្ឋបាល របស់រាជរដ្ឋាភិបាលយ៉ាងធ្ងន់ធ្ងរ ។

ដូច្នេះដើម្បីទប់ស្កាត់រាល់សេចក្តីសម្រេចរបស់តុលាការគ្រប់ជាន់ថ្នាក់ ដែលបានសម្រេចតាមអំណាចសាលក្រមប្រកាសបណ្តឹង ដើម្បីកែប្រែ ឬ ផ្លាស់ប្តូរឈ្មោះ ឬ កែប្រែអាយុតាមពាក្យប្តឹងសុំរបស់ប្រជាពលរដ្ឋ ឬ មន្ត្រីរាជការដោយពុំមានមូលដ្ឋានច្បាប់ជាបង្អែកតទៅទៀតនោះ ក្រសួងយុត្តិធម៌សូមលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង បញ្ឈប់នូវការសម្រេចសេចក្តីបែបនេះជាបណ្តោះអាសន្ន រហូតដល់មានច្បាប់កំណត់អំពីគោលការណ៍នេះច្បាស់លាស់សិន ដើម្បីចូលរួមអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាល និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យជូនរដ្ឋ ។

ក្រសួងយុត្តិធម៌សង្ឃឹមថា ប្រធានតុលាការនិងលោកព្រះរាជអាជ្ញាខេត្ត-ក្រុង ទាំងអស់ និងទទួលអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ដើម្បីចូលរួមអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋ របស់រាជរដ្ឋាភិបាល ឱ្យទទួលបានជោគជ័យពុំខានឡើយ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០២

**រដ្ឋមន្ត្រី**

**<u>ចម្លងជូន</u>**

-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ខុទ្ទកាល័យព្រឹទ្ធសភា និងរដ្ឋសភា
-ខុទ្ទកាល័យ ទីស្តីការគណៈរដ្ឋមន្ត្រី
-តុលាការកំពូល និង មហាអយ្យការតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការសាលាឧទ្ធរណ៍
-តុលាការ និង អយ្យការយោធា
-ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
-ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
-ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
-ដើម្បីជូនជ្រាប